ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៣១ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០៤

## ប្រកាស

## ស្តីពី

## ការសំរួលប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ដែលប្រកាសអោយប្រើ ច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានកែប្រែដោយច្បាប់ស្តីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខនស/រកម /១០០៤/ ០០៥ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីបទបញ្ជា ទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីប្រព័ន្ធគណនីរបស់រតនាគារជាតិ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : - ត្រូវបានចាត់ថ្នាក់គណនីនៃប្លង់គណនេយ្យទូទៅរបស់រដ្ឋ ជា ៦ ថ្នាក់ មានដូចខាងក្រោមនេះ :

គណនីថ្នាក់ ១ : គណនី លទ្ធផល កំចី

គណនីថ្នាក់ ២ : គណនី អចលនវត្ថុ

គណនីថ្នាក់ ៤ : គណនី តតិយជន

គណនីថ្នាក់ ៥ : គណនី ហិរញ្ញវត្ថុ

គណនីថ្នាក់ ៦ : គណនី បន្ទុក ( ចំណាយថវិកា )

គណនីថ្នាក់ ៧ : គណនី ផល ( ចំណូលថវិកា )

- គណនីចាប់ពីថ្នាក់ ១ រហូតដល់ថ្នាក់ ៥ ហៅថាក្រុមគណនី ស្ថានការណ៍ ឬ គណនីតុល្យការ ។
- គណនីថ្នាក់ ៦ និងថ្នាក់ ៧ ហៅថាក្រុមគណនី អនុវត្តថវិកា ។

**ប្រការ ២** : ត្រូវបានដាក់អោយអនុវត្តនូវភាគទី ១ នៃប្លង់គណនេយ្យទូទៅកែសំរួលនៃគណនេយ្យរដ្ឋ ដែលមានលេខគណនី , ឈ្មោះគណនី និង ប្រព្រឹត្តិកម្មនៃគណនី ដូចមានក្នុងឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ ជំនួសប្លង់គណនេយ្យកន្លងមក ។

**ប្រការ ៣** : គណនីមួយចំនួននៅក្នុងឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ ត្រូវអនុវត្តជាជំហានៗ ទៅតាមការរៀបចំនីតិវិធីលំអិតជាក់ស្តែង ។ ក្នុងពេលដែលមាតិកាថវិកាថ្មីទាក់ទងនឹងគណនីថ្នាក់ ១ , ២ ,៦ និង ៧ពុំទាន់បានអនុវត្ត គណនី ចំណូល ចំណាយថវិកា ( ថ្នាក់ ៩ ) ត្រូវបានអនុវត្តបន្ត ។

**ប្រការ ៤** : រតនាគារជាតិអាចរៀបចំបង្កើតបន្ថែម ជាអនុគណនី និង អនុគណនីបន្តរបស់គណនីនិមួយ ៗ ដើម្បីកត់ត្រាចុះបញ្ជី និង ធ្វើរបាយការណ៍ ទៅតាមតំរូវការចាំបាច់ ។

**ប្រការ ៥** : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៦
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ